**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** ...............០១៤/១៤...........**ក.ប**/ស.ស.ក

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារសម្រាប់តាមដាន វិភាគ និងវាយតម្លៃ ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ-បក ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០១៤-២០១៨ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារសម្រាប់តាមដាន វិភាគ និងវាយតម្លៃ ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **អ៊ិត សំហេង** | រដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម **ពេជ សោភ័ន** | រដ្ឋលេខាធិការ | អនុប្រធាន |



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

| | | | |
|---|---|---|---|
| ៣- ឯកឧត្តម | **ប្រាក់ ចាន់ធឿន** | អគ្គលេខាធិការ នៃអ.គ.ក.ប | សមាជិក |
| ៤- ឯកឧត្តម | **ហេង សួរ** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិកអចិន្ត្រៃយ៍ |
| ៥- ឯកឧត្តម | **សេង សក្ដា** | អគ្គនាយកការងារ | សមាជិក |
| ៦- ឯកឧត្តម | **ឡៅ ហ៊ឹម** | អគ្គនាយក TVET | សមាជិក |
| ៧- ឯកឧត្តម | **ហុង ជឿន** | ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ | សមាជិក |
| ៨- ឯកឧត្តម | **ជិត គន្ធល** | អគ្គាធិការ | សមាជិក |
| ៩- លោក | **អ៊ុក សមវិទ្យា** | នាយកបេឡាជាតិរបបសន្តិសុខសង្គម | សមាជិក |
| ១០-លោក | **ថី ស៊ីម៉ាណែត** | ប្រធាននាយកដ្ឋានផែនការ ស្ថិតិនិងនីតិកម្ម | សមាជិក |
| ១១-លោក | **គង់ ច័ន្ទតារា** | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |

**ប្រការ២.~**

ក្រុមការងារនេះ មានភារកិច្ច ដូចតទៅ៖

- សរុប តាមដាន វិភាគ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨ របស់ក្រសួង។
- កំណត់សូចនាករ និងទិសដៅការងារនានាជូនអង្គភាពក្រោមឱវាទ
- ក្រើនរំលឹក ដាក់វិន័យ និងវិធានការណ៍នានាដល់ថ្នាក់ដឹកនាំ និងមន្ត្រីអង្គភាពណាមួយដែលធ្វេសប្រហែស ឬធ្វើឱ្យខកខានក្នុងការសម្រេចបាននូវសូចនាករ ឬទិសដៅការងារណាមួយ។

**ប្រការ៣.~**

ក្រុមការងារនេះ នឹងរៀបចំកិច្ចប្រជុំប្រចាំខែ នៅរៀងរាល់រសៀលថ្ងៃព្រហស្បតិ៍ នៃសប្តាហ៍ទី៤ នៃខែនីមួយៗ។

**ប្រការ៤.~**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គាធិការនៃអគ្គាធិការដ្ឋាន ឯកឧត្តម លោក ដូចមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៤*

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន ៖**

-គ្រប់ថ្នាក់ដឹកនាំក្រសួង

-គ្រប់អង្គភាពក្រោមឱវាទក្រសួង

"ដើម្បីជូនជ្រាប"

-ដូចប្រការ៤ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ